# ធម្មកថា

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ អំពីកូនប្រុសស្រីតបគុណមាតាបិតា

web site: hoksavann.org

ថ្ងៃទី២៩ កក្កដា ២០០៥

នៅក្នុងគម្ពីរព្រះពុទ្ធសាសនា មានគត្ថីរមង្គលសូត្រជាដើមបានពោលថា ការដឹងថាមាតាបិតាមានគុណហៅថាកតញ្ញូ ហើយបានធ្វើតបហៅថា កតវេទី ។ គុណគឺសេចក្តីល្អរបស់មាតាបិតាមកលើកូនប្រុសស្រី ត្រង់គាត់ទាំងពីរមានព្រហ្មវិហារធម៌ មានមេត្តាជាដើម ហើយបញ្ចេញជាសង្គហធម៌ចិញ្ចឹមបីបាច់រក្សា ឲ្យកូនរស់រានមានជីវិត ហើយបង្ហាត់បង្រៀនឲ្យចេះដឹង ប្រកបដោយសង្គហធម៌៤យ៉ាង មានអប់រំកូនមិនឲ្យធ្វើអំពើបាបជាដើម ដូចបានពោលមកហើយ ក្នុងធម៌ដែលមាតាបិតាសង្គ្រោះកូនប្រុសស្រី ។ ចាស់បូរាណពោលថា មាតាបិតាមានគុណដ៏ធ្ងន់លើសភ្នំព្រះសុមេរុ ជ្រៅជាងមហាសមុទ្រ គឺនិយាយអំពីជំរៅទឹកចិត្តរបស់គាត់មានមេត្តាករុណាជាដើម ដែលមានចំពោះកូនប្រុសស្រី ។ ពាក្យខ្មែរមួយបទពោលថា ម៉ែឪមានគុណ គុណមានទម្ងន់ ធ្ងន់ដូចប្រថពី គ្មានអ្វីនឹងសង គុណលោកទាំងពីរមាសប៉ុនគីរី ថ្លៃពុំស្មើហោង ។ ពាក្យខ្មែរថា គុណឪពុក២០ គុណម្តាយ១២នោះពុំមែននិយាយពីជម្រៅទឹកចិត្តមាតាបិតាទេ គឺនិយាយអំពីអាការៈសាច់ឈាមរបស់កូនកើតពីមាតាបិតាចែកឲ្យ គឺធាតុដីមាន២០ ទឹក១២ នៅអាការៈ៣២ ។

ធម៌ប្រាំយ៉ាងដែលកូនប្រុសស្រីត្រូវបំពេញចំពោះមាតាបិតាខ្លួនគឺ ៖

១- ភរណៈ ប្រែថា ការចិញ្ចឹមមាតាបិតា ។ បានសេចក្តីថា កាលកូននៅតូចមាតាបិតាចិញ្ចឹម លុះដល់ពេលកូនធំពេញរូបពេញរាង ចេះរកស៊ីធ្វើការខ្លួនឯងបានហើយ ត្រូវចិញ្ចឹមមាតាបិតាវិញ ជាពិសេសនៅពេលដែលគាត់មានវ័យចាស់ជរាធ្វើការពុំកើត ។

២- កិច្ចករណៈ ប្រែថា ត្រូវធ្វើការជំនួស ។ បានសេចក្តីថា បើកូនរស់នៅជាមួយមាតាបិតា កូនត្រូវធ្វើការជំនួស ចំពោះការងារណាដែលពិបាកហើយធ្ងន់ ។ បើនៅផ្ទះផ្សេងពីគាត់ កូនត្រូវឧស្សាហ៍អើតមើលមាតាបិតាឲ្យបានញឹកញាប់ ក្រែងគាត់មានបញ្ហាអ្វីមួយត្រូវជួយដោះស្រាយ ដោយតាំងចិត្តថា នឹងរង់ចាំបំរើអ្នកមានគុណគ្រប់ពេលវេលា ។ កូនមិនត្រូវឲ្យមាតាបិតាបំរើខ្លួនរហូតដល់គាត់ចាស់ជរាទេ ព្រោះវ័យនេះត្រូវឲ្យគាត់សំរាកពីការងារ ដើម្បីទុកពេលឲ្យគាត់ធ្វើទានរក្សាសីលចំរើនមេត្តាភាវនាស្តាប់លោកទេសនា ។

៣- កុលវិសំ ថបេស្សាមិ ប្រែថា រក្សាវង្សត្រកូល ។ បានសេចក្តីថា កូនប្រុសស្រីត្រូវរក្សាវង្សត្រកូលមាតាបិតាដែលល្អឲ្យបានគង់វង្ស កុំប្រព្រឹត្តអាក្រក់ដែលនាំឲ្យខូចតម្លៃវង់ត្រកូលរបស់មាតាបិតា ។

៤- ទាយជ្ជំ បដិបជ្ជាមិ ប្រែថា ប្រតិបត្តិឲ្យល្អសមទទួលមត៌ក ។ បានសេចក្តីថា កូនដែលសមគួរជាអ្នកទទួលមត៌ក គឺកូនដែលមានចរិយាសម្បត្តិល្អ យកមត៌កនោះទៅប្រើក្នុងផ្លូវត្រូវ មិនយកទៅប្រើក្នុងអំពើអបាយមុខផ្សេងៗ ។

៥- ទក្ខិណានុប្បទានំ ប្រែថា ការធ្វើបុណ្យទក្ខិណានុប្បទាន ។ បានសេចក្តីថា ពេលដែលមាតាបិតាអនិច្ចកម្មទៅ កូនប្រុសស្រីត្រូវធ្វើបុណ្យឧទ្ទិសកុសលជូនគាត់ ។

ការសង្គ្រោះមាតាបិតាដោយធម៌៥យ៉ាងនេះ គ្រាន់តែធ្វើឲ្យគាត់បានសុខស្រួលក្នុងជីវិតបច្ចុប្បន្នប៉ុណ្ណោះ ប៉ុន្តែជីវិតរបស់មនុស្សសត្វ ត្រូវវិលស្លាប់វិលកើតក្នុងសង្សារវដ្ត ទៅតាមកម្មផលល្អអាក្រក់របស់ខ្លួន ។ ដូច្នេះកូនប្រុសស្រី ត្រូវមានភារកិច្ចមួយទៀតដែលត្រូវបំពេញជូនមាតាបិតា គឺត្រូវណែនាំមាតាបិតា ឬបើគ្មានសមត្ថភាពទេ ត្រូវរកអ្នកសប្បុរសជួយណែនាំមាតាបិតា ឲ្យស្ថិតនៅក្នុងសទ្ធាក្នុងសីលក្នុងចាគៈក្នុងបញ្ញា ។ កុសលធម៌ទាំង៤នេះ សំរាប់ជាទីពឹងរបស់មាតាបិតាក្នុងលោកខាងមុខ ។ សូម្បីព្រះពុទ្ធជាម្ចាស់ ព្រះអង្គសំដែងធម៌ទេសនាប្រោសពុទ្ធមាតានិងពុទ្ធបិតា បង្ហាញមគ្គផលនិព្វន ទុកជាការតបគុណរបស់ព្រះអង្គចំពោះព្រះមាតានិងព្រះបិតា ។៚